# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន
និង សង្គ្រោះជនពិការដោយសារមីន
លេខ ៖ ៣២៩../..អគ../..អធម../..២០២៥

## សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) មានសេចក្តីសោមនស្សរីករាយ សូមគោរពជូនដំណឹងដល់សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា មេត្តាជ្រាបថា អាជ្ញាធរមីន នឹងរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍលើវិស័យមីន (TWG-MA) ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០២៥ នៅសណ្ឋាគារ រ៉េស៊ីដង់សុខាភ្នំពេញ។

ក្រុមការងារ TWG-MA ដើរតួនាទីជាវេទិកាសំខាន់សម្រាប់ការសម្របសម្រួលកៀរគរធនធាន និងកិច្ចពិភាក្សាបច្ចេកទេសកម្រិតគោលនយោបាយ ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាលកម្ពុជា ប្រទេសផ្តល់ជំនួយ ដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល (NGOs) និងវិស័យឯកជន។ វេទិកាអន្តរវិស័យនេះ មានគោលបំណងរួមគ្នាដោះស្រាយបញ្ហាប្រឈមក្នុងវិស័យសកម្មភាពមីន និងធានាការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃយុទ្ធសាស្ត្រជាតិសកម្មភាពមីនឆ្នាំ២០១៨-២០២៥ និងគោលនយោបាយជាតិសកម្មភាពមីនឆ្នាំ ២០២៦-២០៣៥ នាពេលខាងមុខ។

កិច្ចប្រជុំរបស់ TWG-MA នឹងបម្រើជាវេទិកាសម្រាប់ការសន្ទនា ការដោះស្រាយបញ្ហាអន្តរវិស័យ និងការជំរុញកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីដោះស្រាយការគំរាមកំហែងនៃគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) ព្រមទាំងលើកកម្ពស់សុវត្ថិភាព និងភាពធន់នៃប្រជាជនដែលងាយរងគ្រោះ។

កិច្ចប្រជុំរបស់ TWG-MA នេះមានគោលបំណងសម្រេចបាននូវគោលបំណងសំខាន់ៗមួយចំនួន រួមទាំងការបង្ហាញសមិទ្ធផលរួម បញ្ហាប្រឈម និងមេរៀនជាបទពិសោធន៍ដែលទទួលបានពីការអនុវត្តយុទ្ធសាស្ត្រជាតិសកម្មភាពមីនឆ្នាំ ២០១៨-២០២៥ រួមជាមួយនិងទិសដៅយុទ្ធសាស្ត្រឆ្ពោះទៅមុខ។ ជាមួយគ្នានេះ ក៏ផ្តល់នូវការធ្វើបច្ចុប្បន្នភាពលើការរៀបចំគោលនយោបាយជាតិសកម្មភាពមីនឆ្នាំ២០២៦-២០៣៥ និងចែករំលែកផែនការបោសសម្អាតមីន នៃសំណើសុំពន្យារពេលបោសសម្អាតមីនលើកទី៣ របស់កម្ពុជា ក្រោម

អាសយដ្ឋាន ៖ អគារថ្មី ផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ . ទូរស័ព្ទលេខ ៖ ០២៣ ៨៨៥ ៩៤១ . ០២៣ ៨៨១ ៤៩២

អនុសញ្ញាអូតាវ៉ា ក៏ដូចជា ការផ្តល់វេទិកាសម្រាប់ភាគីពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីវិធីពង្រឹងនឹងពង្រីកកិច្ចសហប្រតិបត្តិការ កំណត់ភាពប្រទាក់ក្រឡា និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងសម្រាប់ការអនុវត្តសកម្មភាពមីនប្រកបដោយជោគជ័យ។

អាជ្ញាធរមីន សង្ឃឹមថានឹងមានការចូលរួមយ៉ាងផុលផុស ពីភាគីពាក់ព័ន្ធទាំងអស់នៅក្នុងកិច្ចប្រជុំដ៏សំខាន់នេះ ដែលតំណាងឱ្យជំហានដ៏សំខាន់មួយ ឆ្ពោះទៅរកប្រទេសកម្ពុជាដែលគ្មានផលប៉ះពាល់ដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ តាមរយៈការបន្តកិច្ចសន្ទនា កិច្ចសហការ និងការប្តេជ្ញាចិត្តរួមគ្នា ក្រុមការងារ TWG-MA និងជួយរៀបចំដំណាក់កាលបន្ទាប់នៃផែនការយុទ្ធសាស្ត្រ និងការសម្របសម្រួលប្រតិបត្តិការ។ កិច្ចប្រឹងប្រែងរួមគ្នា យើងអាចជម្នះលើបញ្ហាប្រឈមដែលនៅសេសសល់ និងធានាថាសកម្មភាពមីន នៅតែឆ្លើយតបឱ្យបានទាន់ពេលវេលា ប្រកបដោយបរិយាបន្ន និងជាប្រយោជន៍សម្រាប់ប្រជាជនកម្ពុជា។

ថ្ងៃអង្គារ ៧រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ភ្នំពេញ ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ២០២៥